**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងព័ត៌មាន**

ថ្ងៃព្រហស្បតិ៍ ១១រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២២

លេខ.....០៥៣.............ព.មប្រក

## ប្រកាស
## រដ្ឋមន្ត្រីក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស.រ.ក.ម០៨៩៥០៧ ចុះថ្ងៃទី០១ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសារព័ត៌មាន
- បានឃើញព្រះរាជក្រមលេខនសរកម០១៩៦១៤ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧១អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋានរដ្ឋបាល និងសោតទស្សន៍ ជាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និង អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍
- បានឃើញប្រកាសលេខ២៧៤ ព.ម ប្រក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ របស់ក្រសួងព័ត៌មាន
- យោងតាមស្ថានភាពជាក់ស្តែង

### សម្រេច

**ប្រការ១._**

ត្រូវលុបប្រកាសលេខ ២៧៤ ព.ម ប្រក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ របស់ក្រសួងព័ត៌មាន ដែលអនុញ្ញាតឱ្យលោក ជា លីហ៊ាង កាន់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរលេខ ០៦១៦០៦១៨៥ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ មានអាសយដ្ឋាននៅភូមិមេមត់កណ្តាល ឃុំមេមត់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ បង្កើតសមាគម "អ្នកសារព័ត៌មានកម្ពុជា-អាស៊ាន(ស.អ.ក.អ)" ដែលបានចុះឈ្មោះក្នុងបញ្ជីសមាគមតាមប្រកាសលេខ ២០១០ ប្រក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១ នៅក្រសួងមហាផ្ទៃ មានអាសយដ្ឋានទីស្នាក់ការស្ថិតនៅផ្ទះលេខ៦៦១A ផ្លូវលេខ៧១K ក្រុមទី៩ ភូមិតាងួន២ សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដោយមូលហេតុម្ចាស់អាជ្ញាបណ្ណបានប្រព្រឹត្តិកំហុសខាងក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មានយ៉ាងធ្ងន់ធ្ងរ និងមិនព្រមអនុវត្តតាមការអប់រំណែនាំរបស់ក្រសួងជាអាណាព្យាបាល ដែលផ្ទុយនឹងកិច្ចសន្យារបស់សាមីខ្លួនបានតម្កល់ទុកនៅក្រសួងព័ត៌មាន ។

**ប្រការ២._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៣._**

អគ្គនាយកនៃអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នាយកខុទ្ទកាល័យក្រសួងព័ត៌មាន ប្រធានមន្ទីរព័ត៌មានរាជធានី ខេត្ត សាមីខ្លួន និងសមត្ថកិច្ចពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ខៀវ កាញារីទ្ធ**

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- សាលារាជធានី ខេត្ត
- គ្រប់សមាគមសារព័ត៌មាន "ដើម្បីជូនជ្រាប"
- ដូចប្រការ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ